# អ្នកបានទទួលវ៉ាក់សាំង Johnson & Johnson (Janssen) ហើយ

## ព័ត៌មានសំខាន់ សំរាប់អស់អ្នកដែលទទួល វ៉ាក់សាំង COVID-19

សូមអរគុណ សំរាប់ការទទួល វ៉ាក់សាំង COVID-19។ អ្នកគឺជាផ្នែកមួយដ៏សំខាន់ នៃការខំប្រឹងប្រែងរបស់យើង ដើម្បីបញ្ឈប់ការឆ្លងរាលដាល និងរក្សាសហគមន៍របស់យើង ឲ្យបានសុខសប្បាយ។

## អ្នកមិនទាន់បានចាក់ពេញ នៅឡើយទេ!

អ្នកនឹងមិនបានចាក់ពេញទេ រហូតទាល់តែពីរអាទិត្យ បន្ទាប់ពីអ្នកបានទទួលវ៉ាក់សាំង Johnson & Johnson។ ទំរាំដល់ពេលនោះ អ្នកនៅតែអាចកើត និងចំឡងជំងឺ COVID-19 ទៀត។ ចូរបន្តអនុវត្តទំលាប់ ដើម្បីកាត់បន្ថយការរាលដាល។



លាងដៃរបស់អ្នក



ពាក់ម៉ាស្គ




រក្សាគម្លាតរបស់អ្នក



ជៀសវាងក្រុមមនុស្ស

មិនមែនគ្រប់ៗគ្នានឹងបានចាក់វ៉ាក់សាំង នៅពេលអ្នកចាក់ឡើយ។ ហើយក្នុងខណៈយើងដឹង ថាវាកាត់បន្ថយរោគសញ្ញាបានច្រើន យើងក៏កំពុងតែសិក្សាទៀត អំពីការការពាររបស់វ៉ាក់សាំង ប្រឆាំងនឹងការកើតជំងឺ COVID-19 ក្នុងលក្ខណៈជីវិតពិត។

## មនុស្សជាច្រើន ជួបប្រទះឥទ្ធិពលរាយរង បន្តិចបន្តួច ប៉ុន្តែឥទ្ធិពលរាយរងធំដុំ គឺកម្រមាន

ឥទ្ធិពលរាយរងធ្ងន់ធ្ងរ មកពីវ៉ាក់សាំង រួមទាំងវ៉ាក់សាំង COVID-19 គឺកម្រមាន។ ឥទ្ធិពលរាយរងទូទៅបំផុត គឺតូចតាច និងមាន៖

- ឈឺនៅកន្លែងចាក់
- អស់កំឡាំង
- ឈឺសាច់ដុំ និង/ឬ ឈឺសន្លាក់ឆ្អឹង
- ស្រៀវស្រាញ
- ឈឺក្បាល
- គ្រុន

ឥទ្ធិពលរាយរងទាំងនេះ អាច បិតថេរជាច្រើនថ្ងៃ ប៉ុន្តែមិនបណ្តាលឲ្យភ្ញាក់ផ្អើលឡើយ។ បើសិនមានឈឺនៅកន្លែងចាក់មិនបាត់សោះ ឬអ្នកបានព្រួយបារម្ភ សូមទាក់ទងវេជ្ជបណ្ឌិតរបស់អ្នក។ បើសិនអ្នកពុំមានវេជ្ជបណ្ឌិតថែទាំជាបឋមទេ ឬប្រាថ្នាចង់រាយការណ៍ ឥទ្ធិពលរាយរងអ្វីមួយទៅ CDC ទស្សនា cdc.gov/vsafe

ទទួលការថែទាំសុខភាពភ្លាមៗ បើសិនអ្នកកើតមានរោគសញ្ញាអ្វីមួយខាងក្រោម ក្នុងពេលបីអាទិត្យ បន្ទាប់ពីទទួលវ៉ាក់សាំង **Johnson & Johnson COVID-19៖**

- ឈឺក្បាលធ្ងន់ធ្ងរ ឬស្រវាំងភ្នែក
- ដកដង្ហើមផុតៗ
- ឈឺទ្រូង
- ហើមជើង
- ឈឺដំបារពោះដែលមិនបាត់
- ជាំស្បែកដោយងាយៗ ឬកកឈាមតូចៗ នៅក្រោមស្បែក

សំរាប់ព័ត៌មានថែមទៀត ទស្សនា **Mass.gov/COVIDvaccine**